ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

លេខ : ✓ មស.

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## លទ្ធផលជោគជ័យនៃការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងជូនមន្ត្រីរាជការស៊ីវិល

ក្រសួងមុខងារសាធារណៈ មានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជន ពិសេសមន្ត្រីរាជការស៊ីវិលនិងមន្ត្រីសាធារណៈផ្សេងទៀត ដែលស្ថិតក្នុងតារាងបៀវត្សគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ ឱ្យបានជ្រាបថា គិតត្រឹមថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩នេះ ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងបានទទួលជោគជ័យគួរជាទីមោទនៈ។ ទាំងនេះគឺជាការឆ្លើយតបនឹងការសន្យានិងការប្តេជ្ញាចិត្តខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភា ក្នុងក្របខណ្ឌនៃការបង្កើនបៀវត្ស និងការបើកផ្តល់បៀវត្សឱ្យបានឆាប់រហ័ស ទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

លទ្ធផលទាំងនេះ គឺបានមកពីការខិតខំប្រឹងប្រែងរួមគ្នា របស់ក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា ក្នុងការរៀបចំនិងអនុវត្តនីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សរៀងរាល់ពីរសប្តាហ៍ម្តងជូនមន្ត្រីរាជការស៊ីវិលនិងមន្ត្រីសាធារណៈផ្សេងទៀត ក្នុងគោលដៅលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់មន្ត្រីរាជការប្រកបដោយភាពថ្លៃថ្នូរ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩

ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh